**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥៩. អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ឱ្យទៅជា អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ចំណុះក្រសួងពាណិជ្ជកម្ម

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន

-បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សម្រេច

**មាត្រា ១.-**

ត្រូវបានដំឡើង នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) នៃក្រសួងពាណិជ្ជកម្ម ដែលមានចែងក្នុងអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម ឱ្យទៅជា អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ចំណុះក្រសួងពាណិជ្ជកម្ម។

**មាត្រា ២.-**

អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ(កាំកុងត្រូល) មានបេសកកម្មដូចតទៅ ÷

- ធានាគុណភាព សុវត្ថិភាពផលិតផល និងសេវា និងការពារអ្នកប្រើប្រាស់
- ធានាកិច្ចការពារពាណិជ្ជកម្មប្រកបដោយសមធម៌
- ធានាអនុលោមភាពនៃបណ្ណល័ក្ខខ័ណ្ឌតម្រូវផ្នែកច្បាប់ពាក់ព័ន្ធនឹងពាណិជ្ជកម្ម
- ទទួលធ្វើសេវាត្រួតពិនិត្យពាណិជ្ជកម្ម ជាលក្ខណៈភាគីទី ៣
- ជំរុញឱ្យផលិតផលម្ហូបអាហារ ផលិតផលមិនមែនម្ហូបអាហារ លក់លើទីផ្សារមានគុណភាព សុវត្ថិភាព ការពារផលប្រយោជន៍អ្នកប្រើប្រាស់ ។

**មាត្រា ៣.-**

អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ(កាំកុងត្រូល) មានភារកិច្ចដូចតទៅ ÷

- ផ្តល់សេវាត្រួតពិនិត្យទំនិញនាំចេញ នាំចូលរួមជាមួយស្ថាប័នគយ និងរដ្ឋាករផ្នែកលើកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ
- ការពារអ្នកប្រើប្រាស់ ធានាគុណភាព សុវត្ថិភាពផលិតផលទំនិញ និងបង្ក្រាបការក្លែងបន្លំ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ
- ធ្វើវិញ្ញាបនបត្រកម្ម ចំពោះទំនិញនាំចេញ តាមសំណើរបស់អ្នកស្នើសុំ ដើម្បីបំពេញល័ក្ខខ័ណ្ឌតម្រូវនៃប្រទេសនាំចូល
- ត្រួតពិនិត្យភាពអនុលោមតាមស្តង់ដារជាតិ នូវគុណភាព សុវត្ថិភាពផលិតផលទំនិញ ដែលមានប្រើសញ្ញាស្តង់ដារជាតិ
- សហការត្រួតពិនិត្យជាមុននូវប្រតិវេទន៍ នៃផលិតផលទំនិញ ឬសេវាទាំងឡាយណាដែលអាចប៉ះពាល់ដល់សុវត្ថិភាព សុខភាពនៃអ្នកប្រើប្រាស់ ឬ ផលិតកម្ម ឬពាណិជ្ជកម្ម នៃផលិតផលទំនិញ និងសេវាកម្មទាំងនោះដែលផ្តល់ដោយស្ថាប័នមានសមត្ថកិច្ច
- ត្រួតពិនិត្យផលិតផលទំនិញ និងសេវា ក្នុងតំណាក់កាលធ្វើចរាចរណ៍ពាណិជ្ជកម្មលើទីផ្សារ
- គ្រប់គ្រងមន្ទីរពិសោធន៍របស់ក្រសួងពាណិជ្ជកម្ម ដើម្បីវិភាគគុណភាពផលិតផលទំនិញ
- ផ្តល់សេវាត្រួតពិនិត្យលក្ខណៈពាណិជ្ជកម្ម
- ប្រមូលកម្រៃសេវាត្រួតពិនិត្យទំនិញនាំចេញ នាំចូល និងកម្រៃវិភាគគុណភាពទំនិញ
- ជាលេខាធិការដ្ឋាន នៃគណៈកម្មាធិការកូដិច (Codex)ជាតិ
- ជាចំណុចទាក់ទងសម្រាប់ទទួល និងផ្តល់ព័ត៌មានពីអនាម័យ និងភូតគាមអនាម័យ
- ជាចំណុចទំនាក់ទំនងផ្តល់ព័ត៌មានអំពីសុវត្ថិភាពម្ហូបអាហារ ក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការចិន-អាស៊ាន
- អនុវត្តភារកិច្ចពាក់ព័ន្ធផ្សេងៗទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន ។

អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ(កាំកុងត្រូល)ដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ៤.-**

អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) មាននាយកដ្ឋានចំណុះចំនួន ០៤(បួន)នៅថ្នាក់កណ្តាល និងអង្គភាពមូលដ្ឋាន ដូចតទៅ ÷

**ក. ថ្នាក់កណ្តាល ៖**

- នាយកដ្ឋានដោះស្រាយវិវាទ និងគោលនយោបាយទូទៅ
- នាយកដ្ឋានបច្ចេកទេស និងទំនាក់ទំនងសាធារណៈ
- នាយកដ្ឋានកិច្ចការការពារអ្នកប្រើប្រាស់ និងបង្ក្រាបការក្លែងបន្លំ
- នាយកដ្ឋានមន្ទីរពិសោធន៍

**ខ. អង្គភាពមូលដ្ឋាន ៖**

- សាខាខេត្ត ក្រុង និងមជ្ឈមណ្ឌលត្រួតពិនិត្យ និងផែស្ងួត ។

អង្គការលេខរបស់អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ៥.-**

នាយកដ្ឋានដោះស្រាយវិវាទ និងគោលនយោបាយទូទៅ មានភារកិច្ចដូចតទៅ ÷

- រៀបចំ គ្រប់គ្រង និងថែរក្សាសំណុំលិខិតរបស់មន្ត្រីរាជការក្នុងអគ្គនាយកដ្ឋាន
- រៀបចំកម្មវិធីបណ្តុះបណ្តាល
- សម្របសម្រួលការងារផ្ទៃក្នុងអគ្គនាយកដ្ឋានជាមួយអង្គភាពខាងក្រៅ និងសាខាចំណុះ
- គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលរបស់អគ្គនាយកដ្ឋាន និងឯកសារពាក់ព័ន្ធ
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ និងឯកសារសារពើភណ្ឌ
- រៀបចំ គ្រប់គ្រង និងដំណើរការការងារគណនេយ្យ ហិរញ្ញវត្ថុក្នុងអគ្គនាយកដ្ឋាន
- រួមពិនិត្យសេចក្តីព្រាងច្បាប់ បញ្ញត្តិបច្ចេកទេសពាក់ព័ន្ធនឹងផលិតផល
- ផ្តល់មតិលើទិដ្ឋភាពច្បាប់ លើការបកស្រាយច្បាប់
- ពិនិត្យកិច្ចការផ្នែកច្បាប់ លើការប្តឹងផ្តល់ទាំងឡាយទាក់ទងនឹងគុណភាព សុវត្ថិភាព និងការក្លែងបន្លំ
- ធ្វើរបាយការណ៍សកម្មភាពរបស់អគ្គនាយកដ្ឋាន បូកសរុបស្ថិតិ
- កសាងព្រឹត្តិប័ត្រព័ត៌មានពាក់ព័ន្ធនឹងអគ្គនាយកដ្ឋាន
- ទំនាក់ទំនងជាមួយប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន
- អនុវត្តភារកិច្ចពាក់ព័ន្ធផ្សេងៗទៀតដែលថ្នាក់ដឹកនាំអគ្គនាយកដ្ឋានប្រគល់ជូន ។

នាយកដ្ឋានដោះស្រាយវិវាទ និងគោលនយោបាយទូទៅ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ៦.-**

នាយកដ្ឋានបច្ចេកទេស និងទំនាក់ទំនងសាធារណៈ មានភារកិច្ចដូចតទៅ ÷

- សិក្សា និងណែនាំមតិ លើទិដ្ឋភាពបច្ចេកទេសផ្នែកគុណភាព សុវត្ថិភាពនៃផលិតផល
- ព្រាងបទប្បញ្ញត្តិបច្ចេកទេសពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពផលិតផល
- រួមផ្តល់មតិបច្ចេកទេស លើកម្មវិធីធ្វើអង្កេតទូទាំងប្រទេស
- ទំនាក់ទំនងជាមួយស្ថាប័នស្តង់ដារ ស្ថាប័នត្រួតពិនិត្យផ្សេងៗ និងអ្នកមានមុខរបរពាក់ព័ន្ធ
- រួមកសាងកម្រងព័ត៌មាននៃគ្រោះសម្រាប់កិច្ចការវាយតម្លៃគ្រោះនៃផលិតផល
- ទទួលផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការអនុវត្តវិធានការអនាម័យ និងភូតគាមអនាម័យ ក្នុងវិស័យពាណិជ្ជកម្មអន្តរជាតិ

- សម្របសម្រួល សហការប្រមូលផ្តុំព័ត៌មាន ជាមួយគណៈកម្មាធិការកូដិច(Codex)ជាតិ និងស្ថាប័នពាក់ព័ន្ធ ក្នុងការផ្តល់ចម្លើយជូនលេខាធិការដ្ឋានអាស៊ាន លេខាធិការដ្ឋានអង្គការពាណិជ្ជកម្មពិភពលោក និងអង្គការពាក់ព័ន្ធដទៃទៀត
- ស្រាវជ្រាវពីវិធានការផ្នែកវិធានការអនាម័យ និងភូតគាមអនាម័យជាក់លាក់ ដែលមានប្រយោជន៍ដល់ការនាំចេញរបស់កម្ពុជា
- ផ្តល់គំនិតជូនលេខាធិការដ្ឋានគណៈកម្មាធិការកូដិច(Codex)ជាតិ អំពីផលប៉ះពាល់ដល់កម្ពុជានៃបណ្តាការងារកសាងស្តង់ដារម្ហូបអាហារ បញ្ហាត្រួតពិនិត្យម្ហូបអាហារ និងបញ្ហាភូតគាមអនាម័យ
- ធ្វើការផ្សព្វផ្សាយអនុវត្តក្នុងប្រទេសនូវព័ត៌មាន អំពីបណ្តាវិធានការទាក់ទងនឹងអនាម័យ និងភូតគាមអនាម័យ
- ជំនួយការងារផ្នែកលេខាធិការ និងរដ្ឋបាល សម្រាប់លេខាធិការដ្ឋានគណៈកម្មាធិការកូដិច(Codex)ជាតិ
- ប្រមូលផ្តុំគ្រប់គ្រងរក្សាឯកសារវិទ្យាសាស្ត្របច្ចេកទេស ស្តង់ដារ និងបញ្ញត្តិបច្ចេកទេស
- ទទួលបន្ទុកនូវដំណើរការ និងបច្ចុប្បន្នភាព នៃគេហទំព័ររបស់អគ្គនាយកដ្ឋាន
- ទទួលបន្ទុកជាចំណុចទំនាក់ទំនងថ្នាក់ជាតិ នៃប្រព័ន្ធបញ្ជូនព័ត៌មាន ពីសុវត្ថិភាពផលិតផលម្ហូបអាហារ សម្រាប់តំបន់អាស៊ាន និងតំបន់ផ្សេងទៀតទៅតាមការជាក់ស្តែង
- ទទួលបន្ទុកជាចំណុចទំនាក់ទំនងថ្នាក់ជាតិ នៃប្រព័ន្ធបញ្ជូនព័ត៌មានលើផលិតផលប្រើប្រាស់ (ក្រៅពីម្ហូបអាហារ) មិនប្រកបដោយសុវត្ថិភាព សម្រាប់តំបន់អាស៊ាន និងតំបន់ផ្សេងទៀត ទៅតាមការជាក់ស្តែង
- រៀបចំគោលនយោបាយជាតិ អំពីគុណភាព និងសុវត្ថិភាពនៃផលិតផល និងសេវា
- កំណត់វិធីសាស្ត្រត្រួតពិនិត្យ
- ផ្តល់មតិបច្ចេកទេស លើកម្មវិធីធ្វើអង្កេត ផ្នែកគុណភាព សុវត្ថិភាព
- ស្រាវជ្រាវពីអនាម័យ និងអតិសុខុមជីវសាស្ត្រពាក់ព័ន្ធនឹងម្ហូបអាហារ
- ស្រាវជ្រាវពីអនាម័យកែច្នៃផលិតផលម្ហូបអាហារ
- ស្រាវជ្រាវពីសារធាតុបន្ថែមលើម្ហូបអាហារ ផលិតផលប៉ះពាល់ផ្ទាល់នឹងម្ហូបអាហារ និង ផលិតផលសម្រាប់លាងសំអាត
- ស្រាវជ្រាវពីអាហារូបត្ថម្ភ
- ស្រាវជ្រាវបញ្ហាពាក់ព័ន្ធសារធាតុគីមី និងផលិតផលមិនមែនម្ហូបអាហារ គ្រប់គ្រងដោយបញ្ញត្តិបច្ចេកទេស
- ទំនាក់ទំនងជាមួយអង្គការអន្តរជាតិ និងស្ថាប័នត្រួតពិនិត្យនៃប្រទេសនានា
- សម្របសម្រួលជំនួយបច្ចេកទេស
- អនុវត្តភារកិច្ចពាក់ព័ន្ធផ្សេងៗទៀតដែលថ្នាក់ដឹកនាំអគ្គនាយកដ្ឋានប្រគល់ជូន។

នាយកដ្ឋានបច្ចេកទេស និងទំនាក់ទំនងសាធារណៈ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។

## មាត្រា ៧.-

នាយកដ្ឋានកិច្ចការការពារអ្នកប្រើប្រាស់ និងបង្ក្រាបការក្លែងបន្លំ មានភារកិច្ចដូចតទៅ ÷

- តាមដាន និងសន្និដ្ឋានវាយតម្លៃនូវការងារត្រួតពិនិត្យ និងអង្កេតថ្នាក់ជាតិផ្នែកគុណភាព សុវត្ថិភាពផលិតផលទំនិញ និងសេវា ក្នុងក្របខ័ណ្ឌនៃសមត្ថកិច្ចរបស់អគ្គនាយកដ្ឋាន
- រៀបចំតាក់តែងកែសម្រួលវិធីសាស្ត្រ នៃការងារអង្កេតពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាព ផលិតផល
- រៀបចំតាក់តែងសៀវភៅណែនាំការត្រួតពិនិត្យ

- រៀបចំកសាងកម្រងព័ត៌មាន នៃគ្រោះសម្រាប់ការអនុវត្តកិច្ចត្រួតពិនិត្យការនាំចេញ នាំចូល ដោយផ្អែកលើគោលការណ៍នៃការគ្រប់គ្រងហានិភ័យ
- រាប់រងបន្ថែមជាមួយសាខានូវកិច្ចការត្រួតពិនិត្យតាម ខេត្ត ក្រុង សម្រាប់អនុវត្តកិច្ចការអង្កេតពិសេសទាំងឡាយ
- ដឹកនាំក្រុមអង្កេតពិសេស សម្រាប់អនុវត្តកិច្ចការអង្កេតពិសេសនានា ដែលមានលក្ខណៈបច្ចេកទេសស្មុគស្មាញ
- កសាងគោលនយោបាយកិច្ចការអ្នកប្រើប្រាស់ពាក់ព័ន្ធនឹងទំនិញ សេវាកម្ម ជាអាទិ៍ ការដាក់ ស្លាកសញ្ញា ការឃោសនាពាណិជ្ជកម្មភូតកុហក ការបន្លំពាក់ព័ន្ធនឹងផលិតផល និងសេវាកម្ម
- រៀបចំកម្មវិធីតាមដាន និងសន្និដ្ឋានវាយតម្លៃការងារអង្កេតថ្នាក់ជាតិពាក់ព័ន្ធនឹងកិច្ចការអ្នកប្រើប្រាស់ក្រៅពីបញ្ហាគុណភាព សុវត្ថិភាពផលិតផល និងសេវា
- ទទួលពិនិត្យដោះស្រាយ នូវពាក្យបណ្តឹងតវ៉ារបស់សាធារណជន ឬស្ថាប័នសាធារណៈ
- ជំរុញបង្កើត ឬ គាំទ្រចលនាអ្នកប្រើប្រាស់
- រៀបចំអនុវត្តកម្មវិធីផ្តល់ព័ត៌មានអប់រំ និងផ្តល់ការយល់ដឹងដល់អ្នកប្រើប្រាស់
- ដឹកនាំ សម្របសម្រួល និងអនុវត្តកិច្ចការត្រួតពិនិត្យពាណិជ្ជកម្មពាក់ព័ន្ធដល់ការនាំចូល និង នាំចេញទំនិញ ឬការប្រគល់ទទួលក្នុងប្រទេសតាមសំណើរបស់ការិសេដ្ឋកិច្ច
- អនុវត្តភារកិច្ចពាក់ព័ន្ធផ្សេងៗទៀតដែលថ្នាក់ដឹកនាំអគ្គនាយកដ្ឋានប្រគល់ជូន ។

នាយកដ្ឋានកិច្ចការការពារអ្នកប្រើប្រាស់ និងបង្ក្រាបការក្លែងបន្លំ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ៨.-**

នាយកដ្ឋានមន្ទីរពិសោធន៍ មានភារកិច្ចដូចតទៅ ÷

- រៀបចំឱ្យមានប្រព័ន្ធធានាគុណភាពសម្រាប់មន្ទីរពិសោធន៍ និងអនុវត្តការងារតាមប្រព័ន្ធនេះឱ្យមានប្រសិទ្ធភាព
- កសាងកម្មវិធីត្រួតពិនិត្យគុណភាពសម្រាប់ការធ្វើតេស្ត (Quality Control Programs for Testing) និងឯកសារស្តីពីប្រព័ន្ធគុណភាព ជាអាទិ៍គោលនយោបាយ និងវិធានការងារ វិធីសាស្ត្រ កំណត់ត្រាទម្រង់ឯកសារ និងស្តង់ដារ សម្រាប់អនុវត្តការងារមន្ទីរពិសោធន៍
- ទទួលធ្វើតេស្ត និងយកគំរូសម្រាប់ធ្វើតេស្តកំណត់ចរិតលក្ខណៈ រូប គីមី និងមីក្រូជីវសាស្ត្រលើផលិតផលម្ហូបអាហារ និងផលិតផលមិនមែនម្ហូបអាហារ ទៅតាមវិសាលភាពដែលបានកំណត់ជាក់លាក់
- អនុវត្តកម្មវិធីត្រួតពិនិត្យគុណភាពខាងក្រៅ ( External Quality Control Programs ) ដោយសហការជាមួយមន្ទីរពិសោធន៍ដទៃទៀត។ ចូលរួមក្នុងការត្រួតពិនិត្យនិងវាយតម្លៃ ប្រសិទ្ធភាពធ្វើតេស្តរបស់មន្ទីរពិសោធន៍ ជាមួយអន្តរមន្ទីរពិសោធន៍ ក្នុងកម្មវិធីធ្វើពិសោធន៍ដែលមានប្រសិទ្ធភាព (Proficiency Testing Schemes) ដែលរៀបចំឡើងដោយស្ថាប័នទទួលស្គាល់អន្តរជាតិ
- រៀបចំកម្មវិធី និងនីតិវិធីយកគំរូផលិតផលម្ហូបអាហារ និងមិនមែនម្ហូបអាហារសម្រាប់អនុវត្ត នៅតាមសាខាកាំកុងត្រូលប្រចាំខេត្ត ក្រុង តាមដានការអនុវត្តការងារនេះ ទទួលវិភាគ វាយតម្លៃភាពសមស្របរបស់ផលិតផល រក្សា និងគ្រប់គ្រងទិន្នន័យ វិភាគឱ្យបានត្រឹមត្រូវ
- រៀបចំយុទ្ធសាស្ត្រ ផែនការ និងសំណូមពរ សម្រាប់អភិវឌ្ឍសមត្ថភាពធ្វើតេស្តរបស់មន្ទីរពិសោធន៍ស្របតាមស្ថានភាពជាក់ស្តែង និងការតម្រូវចាំបាច់
- រៀបចំឱ្យមានការធ្វើសវនកម្មផ្ទៃក្នុងលើការអនុវត្តការងាររបស់មន្ទីរពិសោធន៍ តាមពេលវេលាកំណត់ជាក់លាក់

- កំណត់វិសាលភាពតេស្តសម្រាប់ការស្នើសុំវាយតម្លៃលើសមត្ថភាព ពីស្ថាប័នទទួលស្គាល់អន្តរជាតិ រៀបចំ និងចាត់ចែងការងារនេះឱ្យបានត្រឹមត្រូវតាមល័ក្ខខ័ណ្ឌតម្រូវ ដើម្បីទទួលបានការទទួលស្គាល់ផ្លូវការ លើសមត្ថភាពរបស់មន្ទីរពិសោធន៍
- អនុវត្តភារកិច្ចពាក់ព័ន្ធផ្សេងៗទៀតដែលថ្នាក់ដឹកនាំអគ្គនាយកដ្ឋានប្រគល់ជូន ។

នាយកដ្ឋានមន្ទីរពិសោធន៍ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

**មាត្រា ៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**កន្លែងទទួល :**

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី*
*-ដូចមាត្រា ១០*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

## ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខៈ ៥៩ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៨

## អង្គការលេខរបស់អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល)

